**<u>មេរៀនសង្ខេប</u>**

- ស៊ីមណ្ឌស្ពៃមជាប្រភេទរុក្ខជាតិគ្រាប់ននល។ វាជារុក្ខជាតិមានគ្រាប់ទី1នៅលើផែនដី ដែលស៊ីមណ្ឌស្ពៃមភាគច្រើនជារុក្ខជាតិឈើធំៗ មានដើមទោលហើយត្រង់ ។ ស្លឹកស៊ីមណ្ឌស្ពៃម មានរាងផ្សេងៗ ដូចស្លឹកដូង កង្ហារ រាងស្រកា និងរាងមូល ។
- ស៊ីមណ្ឌស្ពៃមមាន ៤ក្រុមគឺ ប្រង់ កូនីភែ គីងកូ និង ស៊ីណេតូភីត។
- សរីរាង្គលូតលាស់របស់ស៊ីមណ្ឌស្ពៃម មានដើម ស្លឹក ។
- សរីរាង្គបន្តពូជស៊ីមណ្ឌស្ពៃម ហៅថាកោនដែលគ្របដណ្តប់ដោយស្រកា។ កោនឈ្មោលផលិតគ្រាប់លំអងដែលក្រោយមកក្លាយជាស្ពៃម៉ាតូសូអ៊ីត ។ អូវុលលូតលាស់ក្នុងកោនញីដែលផ្ទុក អូអូស្វ៊ែ ។ បន្ទាប់ពីការបង្កកំណើតអូវុលលូតលាស់ទៅជាគ្រាប់ ។ ពេលគ្រាប់ទុំ ស្រកាបើក គ្រាប់ជ្រុះទៅលើដី។កាលណាជួបលក្ខខណ្ឌសមស្រប គ្រាប់លូតលាស់ទៅជារុក្ខជាតិថ្មី ។